# មាតិកា

## I-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រម


*-ព្រះរាជក្រម នស/រកម/១២១៥/០១៧ មិនទាន់បានទទួល*

២៤-១២-២០១៥ -ព្រះរាជក្រម នស/រកម/១២១៥/០១៨ ស្ដីពី ការប្រកាសឱ្យប្រើ ច្បាប់ ស្ដីពី ស្ថិតិ ១


### ២-ព្រះរាជក្រឹត្យ


២៨-១២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/១២១៥/១១៤៨ ស្ដីពី ការតែងតាំងលោកជំទាវ **ឆោម សោភ័ណ្ឌ** ជាទីប្រឹក្សាផ្ទាល់សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ដោយមិនយកប្រាក់បៀវត្ស ១៣

២៨-១២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/១២១៥/១១៤៩ ស្ដីពី ការតែងតាំងឯកឧត្ដម ចំនួន ០២ រូប ជាទីប្រឹក្សាសម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ១៤

២៨-១២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/១២១៥/១១៥០ ស្ដីពី ការតែងតាំង និងផ្ដល់ឋានៈ ជាជំនួយការសម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ចំនួន ០២ រូប មានឋានៈស្មើ អគ្គនាយក ដោយមិនយកប្រាក់បៀវត្ស ១៥

២៨-១២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/១២១៥/១១៥១ ស្ដីពី ការតែងតាំងនិងផ្ដល់ឋានៈ ជាទីប្រឹក្សា ជំនួយការសម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ចំនួន ០២ រូប ១៦

២៨-១២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/១២១៥/១១៥២ ស្ដីពី ការតម្លើងឋានន្តរស័ក្តិ ជាករណីពិសេសដល់ឯកឧត្ដម **ហ៊ុំ ណារុធ** នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ១៧

២៨-១២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/១២១៥/១១៥៣ ស្ដីពី ការតម្លើងថ្នាក់ ជាករណីពិសេសដល់លោក **ឌឹម សុខខុន** នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ១៨

២៨-១២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/១២១៥/១១៥៤ ស្ដីពី ការផ្ទេរក្របខ័ណ្ឌលោក **យ៉ែម ច័ន្ទណារ៉ុំ** នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ មកក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ក្រសួងមហាផ្ទៃ ១៩

២៨-១២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/១២១៥/១១៥៦ ស្ដីពី ការតម្លើងឋានន្តរស័ក្តិដល់ នាយនគរបាលថ្នាក់ឧត្ដមសេនីយ៍ និងនាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ១៩ រូប ២០

២៨-១២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/១២១៥/១១៥៨ ស្តីពី ការតម្លើងឋានន្តរស័ក្តិឧត្តមសេនីយ៍ត្រី ដល់នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ០៣ រូប ២២

២៨-១២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/១២១៥/១១៥៩ ស្តីពី ការតម្លើងឋានន្តរស័ក្តិដល់ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ និងនាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ០២ រូប ២៣

២៨-១២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/១២១៥/១១៦០ ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌដល់មន្ត្រីរាជការ ២០ រូប នៅក្រសួងអប់រំ យុវជន និង កីឡា ២៤

២៨-១២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/១២១៥/១១៦១ ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការចំនួន ១៦ រូប នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ២៦

២៨-១២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/១២១៥/១១៦២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ លោក **Huang Xinglong** ២៨

## II-រាជរដ្ឋាភិបាល

## អនុក្រឹត្យ

១១-១២-២០១៥ -អនុក្រឹត្យលេខ ១៧១ អនក្រ.បក ស្តីពី ការដាក់ឱ្យអនុវត្តកម្មវិធីកាត់បន្ថយ និង/ឬលុបបំបាត់ពន្ធគយរបស់ព្រះរាជាណាចក្រកម្ពុជា ស្របតាមនាមវលីនៃតារាងពន្ធគយសុខដុមរបស់អាស៊ាន ឆ្នាំ ២០១២ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន ២៩

៣១-១២-២០១៥ -អនុក្រឹត្យលេខ ១៩៤ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៦៥

៣១-១២-២០១៥ -អនុក្រឹត្យលេខ ១៩៥ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៦៧

៣១-១២-២០១៥ -អនុក្រឹត្យលេខ ១៩៦ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៦៩

៣០-១២-២០១៥ -អនុក្រឹត្យលេខ ១២៧៤ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ ៧១

៣០-១២-២០១៥ -អនុក្រឹត្យលេខ ១២៧៥ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៧៣

០៤-០១-២០១៦ -អនុក្រឹត្យលេខ ០១ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៧៥

០៤-០១-២០១៦ -អនុក្រឹត្យលេខ ០២ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ៧៧

០៤-០១-២០១៦ -អនុក្រឹត្យលេខ ០៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៧៨

## III-ការងារបណ្ដាក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


២៣-១២-២០១៥ -ប្រកាសលេខ ១៧៩៦ សហវ.ប្រក ស្តីពី ការបង្កើត និងដាក់ឱ្យដំណើរការ អង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ៨០

២៥-១២-២០១៥ -ប្រកាសលេខ ១៨២៣ សហវ.ប្រក ស្តីពី ស្តង់ដារនៃសេវាសាធារណៈរបស់ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ៨៣


### ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម


២៧-១០-២០១៥ -ប្រកាសលេខ ៦២៦ ឧស.កឧ.ប្រក.១០ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ម៉ាកាឡូត ហ្គាមេន (ខេមបូឌា) បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៩៣

២៧-១០-២០១៥ -ប្រកាសលេខ ៦២៧ ឧស.កឧ.ប្រក.១០ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ម៉ាកាឡូត ហ្គាមេន (ខេមបូឌា) បង្កើតសាខារោងចក្រ កាត់ដេរសម្លៀកបំពាក់ ៩៦

២៧-១០-២០១៥ -ប្រកាសលេខ ៦២៨ ឧស.កឧ.ប្រក.១០ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ីដ ១៥៣ (ខេមបូឌា) ខូអិលធីឌី បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៩៩

២៧-១០-២០១៥ -ប្រកាសលេខ ៦២៩ ឧស.កឧ.ប្រក.១០ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន សុន ស៊ុយ ស៊ីង អ៊ិនដាសស្ទ្រៀល (ខេមបូឌា) បង្កើតរោងចក្រ ផលិតកាបូបគ្រប់ប្រភេទ ១០២

២៧-១០-២០១៥ -ប្រកាសលេខ ៦៣០ ឧស.កឧ.ប្រក.១០ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជីនម៉ីយ៉ុង ហ្គាមេន ឌីវើឡុបមេន ខប បង្កើតរោងចក្រ បោកគក់ ជ្រលក់ពណ៌ និងបំលែងពណ៌ ១០៥

២៧-១០-២០១៥ -ប្រកាសលេខ ៦៣១ ឧស.កឧ.ប្រក.១០ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ផៅវ័រ ស៊ីហ្គា ថូបែកខូ ខូ អិលធីឌី បង្កើតរោងចក្រ ផលិតបារី ១០៨

៣០-១០-២០១៥ -ប្រកាសលេខ ៦៣៥ ឧស.កឧ.ប្រក.១០ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ុនជាង អ៊ិនធើណេសិនណល (ខេមបូឌា) បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ១១១

៣០-១០-២០១៥ -ប្រកាសលេខ ៦៣៦ ឧស.កឧ.ប្រក.១០ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្គោលឌិន ដួនកែវ រ៉ាយស៍ មីល បង្កើតរោងចក្រ កិនស្រូវ ១១៤

# ព្រះរាជក្រម

នស/រកម/១២១៥/ ០១៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហាតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីស្ថិតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ច្បាប់

# ស្តីពីស្ថិតិ

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងគ្រប់គ្រងការងារទាំងឡាយ ដែលទាក់ទងដល់ការប្រមូល ការកែច្នៃ ការចងក្រង ការវិភាគ ការបោះពុម្ព និងការផ្សព្វផ្សាយទិន្នន័យស្ថិតិ។

**មាត្រា ២.-**

ច្បាប់នេះមានគោលដៅដូចតទៅ ៖

-គាំទ្រសេចក្តីត្រូវការទិន្នន័យស្ថិតិរបស់អ្នកធ្វើគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំ វាយតម្លៃគោលនយោបាយ និងកម្មវិធីសេដ្ឋកិច្ច សង្គមកិច្ច ដែលផ្តោតលើកិច្ចអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងសុខុមាលភាពរបស់ប្រជាជាតិ ក៏ដូចជាសេចក្តីត្រូវការសម្រាប់អ្នកធ្វើសេចក្តីសម្រេច និងអ្នកស្រាវជ្រាវក្នុងសហគមន៍ជាតិនិងអន្តរជាតិដ៏ទូលំទូលាយ

-សម្រួលកិច្ចអភិវឌ្ឍប្រព័ន្ធស្ថិតិជាតិឲ្យមានសមត្ថភាព និងប្រសិទ្ធភាព

-បង្កើនការយល់ដឹងជាសាធារណៈនូវសារៈសំខាន់នៃមុខងារ និងតួនាទីរបស់ស្ថិតិនៅក្នុងកម្មវិធីអភិវឌ្ឍន៍ជាតិ

-លើកទឹកចិត្តដល់កិច្ចអភិវឌ្ឍវិធីសាស្ត្រនិងបច្ចេកវិទ្យានៅក្នុងសកម្មភាពស្ថិតិ ។

**មាត្រា ៣.-**

ច្បាប់នេះមានវិសាលភាពអនុវត្តលើរាល់សកម្មភាពស្ថិតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ មានន័យដូចខាងក្រោម ៖

១-**ស្ថិតិ** សំដៅដល់ទិន្នន័យដែលបានមកដោយការប្រមូល ការកែច្នៃ ការចងក្រង ការវិភាគ ការបោះពុម្ព និងការផ្សព្វផ្សាយលទ្ធផលនៃចម្លើយតាមការប្រមូលស្ថិតិ ឬពីប្រភពទិន្នន័យរដ្ឋបាល ។

២-**ប្រព័ន្ធស្ថិតិជាតិ** សំដៅដល់សមាហរណកម្មនៃស្ថិតិថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងហេដ្ឋារចនាសម្ព័ន្ធស្ថិតិ រួមបញ្ចូលទាំងទិន្នន័យស្ថិតិផ្លូវការ និងកម្មវិធីស្ថិតិជាតិ រចនាសម្ព័ន្ធស្ថិតិ និងអង្គភាពស្ថិតិក្នុងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល ព្រមទាំងមន្ត្រីស្ថិតិ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត ។

៣-**ស្ថិតិគ្រឹះ** សំដៅដល់ស្ថិតិផ្លូវការស្តីពីសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន និងប្រជាសាស្ត្រដែលជាស្ថិតិមានចរិតទាក់ទងនឹងផ្នែកជាច្រើនកម្រិតជាតិ មូលដ្ឋាន ដែលជាតម្រូវការរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំគោលនយោបាយ កម្មវិធី និងការវាយតម្លៃក៏ដូចជាការប្រើប្រាស់ដ៏ទូលាយរបស់សហគមន៍ជាតិ និងអន្តរជាតិ ។

ROYAUME DU CAMBODGE • LE MINISTERE DU PALAIS ROYAL •

៤-**ស្ថិតិតាមវិស័យ** សំដៅដល់ស្ថិតិដែលប្រមូលដោយបណ្តាក្រសួង ស្ថាប័នរាជរដ្ឋាភិបាល សម្រាប់តម្រូវការផ្ទៃក្នុងផ្ទាល់ខ្លួន និងគោលដៅធ្វើរបាយការណ៍ ។

៥-**ជំរឿន** សំដៅដល់ការប្រមូលស្ថិតិពីបុគ្គល គ្រួសារ សហគ្រាស ឬអង្គភាពចាត់តាំងផ្សេងទៀត ដែលអង្គភាពទាំងអស់ត្រូវបានធ្វើសម្ភាសន៍ ។

៦-**អង្កេត** សំដៅដល់ការប្រមូលទិន្នន័យតាមបែបវិទ្យាសាស្ត្រពីបុគ្គល គ្រួសារសហគ្រាស ឬអង្គភាពចាត់តាំងផ្សេងទៀត ដែលអង្គភាពជ្រើសរើសគំរូតែប៉ុណ្ណោះ ត្រូវបានសម្ភាសន៍ ។

៧-**មន្ត្រីស្ថិតិ** សំដៅដល់មន្ត្រីរាជរដ្ឋាភិបាលដែលមានសិទ្ធិអំណាចក្នុងការធ្វើសកម្មភាពស្ថិតិផ្លូវការ ។

៨-**អ្នកឆ្លើយ** សំដៅដល់បុគ្គល គ្រួសារ ក្រុមហ៊ុន សហគ្រាស អង្គភាពសេដ្ឋកិច្ច អាជីវកម្ម សេវាកម្ម ស្ថាប័នរាជរដ្ឋាភិបាលឬសង្គមស៊ីវិល ឬអង្គការផ្សេងទៀត ដែលត្រូវបានជ្រើសរើសក្នុងការជំរឿន និងអង្កេត ។

៩-**ទិន្នន័យ** សំដៅដល់ទិន្នន័យបរិមាណ និងជាទិន្នន័យគុណភាព ។

១០-**ទិន្នន័យបរិមាណ** សំដៅដល់ព័ត៌មានដែលមានរូបភាពជាតួលេខ ។

១១-**ទិន្នន័យគុណភាព** សំដៅដល់ព័ត៌មានដែលមានរូបភាពជាអត្ថបទ ។

១២-**ទិន្នន័យរដ្ឋបាល** សំដៅដល់ទិន្នន័យដែលប្រមូលចងក្រងតាមរយៈកំណត់ត្រាដោយបណ្តាក្រសួងស្ថាប័នសម្រាប់តម្រូវការប្រើប្រាស់របស់ខ្លួន ។

១៣-**ទិន្នន័យផ្តុំ** សំដៅដល់ទិន្នន័យដែលពាក់ព័ន្ធនឹងក្រុមបុគ្គល គ្រួសារសហគ្រាស ឬស្ថាប័នផ្សេងៗ ត្រូវបានប្រមូលផ្តុំក្នុងកម្រិតមួយដែលមិនអនុញ្ញាតឲ្យស្គាល់ទិន្នន័យបុគ្គល ។

១៤-**ទិន្នន័យស្ថិតិជាតិ** សំដៅដល់ទិន្នន័យដែលត្រូវបានផលិតដោយវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិផ្សេងទៀត នៃប្រព័ន្ធស្ថិតិជាតិ ។

១៥-**ស្ថិតិផ្លូវការដែលបានចាត់តាំង** សំដៅដល់ស្ថិតិដែលបានផលិតដោយក្រសួងស្ថាប័នដែលកំណត់ដោយរាជរដ្ឋាភិបាលដើម្បីបម្រើសំណូមពរព័ត៌មានស្ថិតិរបស់អ្នកធ្វើគោលនយោបាយក្នុងការរៀបចំវាយតម្លៃគោលនយោបាយ និងកម្មវិធីសេដ្ឋកិច្ច សង្គមកិច្ច ដើម្បីឆ្លើយតបទៅនឹងកិច្ចអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចរបស់ប្រទេសក៏ដូចជាបម្រើសេចក្តីត្រូវការព័ត៌មានរបស់អ្នកធ្វើសេចក្តីសម្រេច និងអ្នកស្រាវជ្រាវក្នុងសហគមន៍ជាតិ និងអន្តរជាតិដ៏ទូលំទូលាយ ។

១៦-**គោលបំណងស្ថិតិ** សំដៅដល់គោលបំណងដែលទាក់ទងទៅនឹងការប្រមូល ការកែច្នៃ ការចងក្រង ការវិភាគ ការបោះពុម្ពការបញ្ចូលព័ត៌មានទិន្នន័យស្ថិតិតាមប្រព័ន្ធអេឡិចត្រូនិក និងការផ្សព្វផ្សាយស្ថិតិផ្លូវការ ។

១៧-**មេតាទិន្នន័យ** សំដៅដល់ការពិពណ៌នាអំពីទិន្នន័យ ពោលគឺការរៀបរាប់អំពីប្រភពដំណើរការចងក្រង វិធីសាស្ត្រចងក្រង ពេលវេលាផ្សព្វផ្សាយ ស្ថាប័ន និងអ្នកទទួលខុសត្រូវក្នុងការចងក្រង

ដើម្បីឲ្យអ្នកប្រើប្រាស់យល់ដឹងពីទិន្នន័យកាន់តែស៊ីជម្រៅ ។

១៨-**មីក្រូទិន្នន័យ** សំដៅដល់ទិន្នន័យកម្រិតបុគ្គលដែលប្រមូលបានពីការអង្កេត ជំរឿន ឬពីប្រភពរដ្ឋបាល ។

## ជំពូកទី ២
## គោលការណ៍

**មាត្រា ៥.-**

ការអភិវឌ្ឍស្ថិតិត្រូវឈរលើមូលដ្ឋាននៃគោលការណ៍ ភាពត្រឹមត្រូវ ភាពឯករាជ្យ ភាពសត្យានុម័ត ភាពគួរទុកចិត្តបាន ភាពសំខាន់ និងភាពទាន់ពេលវេលា ស្របតាមគោលការណ៍នៃសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ និងប្រព័ន្ធស្ថិតិរបស់សហគមន៍អាស៊ាន ។

## ជំពូកទី ៣
## ការប្រមូលទិន្នន័យស្ថិតិ

**មាត្រា ៦.-**

ទិន្នន័យស្ថិតិត្រូវបានប្រមូលតាមរយៈ ៖

ក-ការធ្វើជំរឿន ។

ខ-ការធ្វើអង្កេត ។

គ-ការទទួលបានទិន្នន័យរដ្ឋបាលពីប្រភពរាជរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល ។

**មាត្រា ៧.-**

ជំរឿនដូចមានចែងក្នុងមាត្រា ៦ កថាខណ្ឌ ក ខាងលើនេះត្រូវដំណើរការយ៉ាងតិចមួយដងក្នុងរយៈពេល ១០ (ដប់) ឆ្នាំ ។

ជំរឿនមាន ៣ ប្រភេទ ៖

ក-ជំរឿនប្រជាជន ។

ខ-ជំរឿនកសិកម្ម ។

គ-ជំរឿនសេដ្ឋកិច្ច ។

ជំរឿនទាំងនេះត្រូវអនុវត្តដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ៨.-**

រាជរដ្ឋាភិបាលត្រូវកំណត់កាលបរិច្ឆេទសម្រាប់ដំណើរការជំរឿនទាំង ៣ ដោយអនុក្រឹត្យក្នុងរយៈពេល ១០ (ដប់) ឆ្នាំម្តង ។ កាលបរិច្ឆេទនេះអាចធ្វើការផ្លាស់ប្តូរបាន ក្នុងករណីចាំបាច់ ។

**មាត្រា ៩.-**

អង្កេតចន្លោះជំរឿនទាំងឡាយ អាចត្រូវបានដំណើរការ ក្នុងចន្លោះជំរឿនពីរសម្រាប់ធ្វើបច្ចុប្បន្នកម្មប្រចាំឆ្នាំនូវទិន្នន័យជំរឿនគោល ដើម្បីចងក្រងស្ថិតិសេដ្ឋកិច្ច និងសង្គមកិច្ចត្រឹមត្រូវគួរទុកចិត្តបាន ដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់អ្នកធ្វើគោលនយោបាយរបស់រាជរដ្ឋាភិបាល និងអ្នកប្រើប្រាស់នានា ។

**មាត្រា ១០.-**

អង្កេតដូចមានចែងក្នុងមាត្រា ៦ កថាខណ្ឌ ខ នៃច្បាប់នេះ ត្រូវដំណើរការតាមពេលកំណត់ ដើម្បីផលិតស្ថិតិជាតិជាគ្រឹះដ៏ត្រឹមត្រូវ គួរទុកចិត្តបាន និងជាពិសេសដើម្បីបម្រើឲ្យសេចក្តីត្រូវការទិន្នន័យស្ថិតិបន្ទាន់របស់រាជរដ្ឋាភិបាល ។ ក្នុងគោលបំណងធ្វើអង្កេតសេដ្ឋកិច្ចវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការត្រូវបង្កើតបញ្ជីពាណិជ្ជកម្ម ឬគ្រោងសំណាកគំរូសម្រាប់អង្កេតដើម្បីរក្សាទុក និងធ្វើបច្ចុប្បន្នកម្មប្រចាំឆ្នាំ ។

**មាត្រា ១១.-**

ស្ថិតិដែលផលិតចេញពីប្រភពទិន្នន័យរដ្ឋបាលដូចមានចែងក្នុងមាត្រា ៦ កថាខណ្ឌ គ នៃច្បាប់នេះត្រូវចងក្រងដោយប្រើប្រាស់ទិន្នន័យកត់ត្រាក្នុងឯកសារ តារាង និងកំណត់ត្រាផ្សេងៗទៀតដែលមានប្រភពពីរាជរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល ។ ក្នុងគោលដៅចងក្រងស្ថិតិពីប្រភពរដ្ឋបាល វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ត្រូវធ្វើសៀវភៅរាយឈ្មោះ និងទីតាំងរបស់ប្រភពទិន្នន័យស្ថិតិ និងរដ្ឋបាលដែលត្រូវថែរក្សា និងធ្វើបច្ចុប្បន្នកម្មប្រចាំឆ្នាំ ។

**មាត្រា ១២.-**

ក្នុងក្របខ័ណ្ឌនៃច្បាប់នេះ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការមានភារកិច្ចទទួលខុសត្រូវក្នុងការ ៖

-ប្រមូល កែច្នៃ ចងក្រង វិភាគ បោះពុម្ព និងផ្សព្វផ្សាយទិន្នន័យស្ថិតិគ្រឹះតាមការធ្វើជំរឿន អង្កេត និងប្រើប្រាស់ប្រភពទិន្នន័យរដ្ឋបាល

-ចងក្រងគណនេយ្យជាតិកម្ពុជា និងសន្ទស្សន៍ថ្លៃក៏ដូចជាសូចនាករសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន និងប្រជាសាស្ត្រ ។

**មាត្រា ១៣.-**

បណ្តាក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល ត្រូវប្រមូលទិន្នន័យតាមផ្នែកដោយខ្លួនឯង ឬដោយសហប្រតិបត្តិការជាមួយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ តាមរយៈ ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

-ការធ្វើអង្កេត

-ការប្រមូលទិន្នន័យស្ថិតិពីការកត់ត្រារដ្ឋបាល ។

## ជំពូកទី ៤
## ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ

### មាត្រា ១៤.-

វិទ្យាស្ថានជាតិស្ថិតិ ស្ថិតក្រោមឱវាទក្រសួងផែនការមានភារកិច្ចកសាងគោលនយោបាយស្ថិតិផ្លូវការក្នុងការបង្កើតប្រព័ន្ធស្ថិតិជាតិរួមបញ្ចូលគ្នាមួយ ដែលគ្របដណ្ដប់ស្ថិតិផ្លូវការដែលបានចាត់តាំងទាំងអស់ និងអង្គភាពស្ថិតិក្នុងក្រសួង ស្ថាប័ន ។ ដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ និងស្ថិតិផ្លូវការដែលបានចាត់តាំង ត្រូវកំណត់ដោយអនុក្រឹត្យ ។

### មាត្រា ១៥.-

ក្នុងភារកិច្ចនេះ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការត្រូវ ៖

ក-ដំណើរការយន្តការសម្របសម្រួលសម្រាប់ធានាការគ្រប់គ្រងដែលមានសមត្ថភាព និងប្រសិទ្ធភាពនៃប្រព័ន្ធស្ថិតិជាតិ ។

ខ-ធ្វើការសម្របសម្រួលក្នុងសកម្មភាពនៃកិច្ចអភិវឌ្ឍស្ថិតិរួម និងការបណ្ដុះបណ្ដាលជាមួយក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងផ្នែកឯកជន ។

គ-ធ្វើកិច្ចសហប្រតិបត្តិការក្នុងសកម្មភាពស្ថិតិ ជាមួយអង្គការអន្តរជាតិ អង្គភាព ស្ថិតិជាតិនៃប្រទេសនានា និងផ្នែកឯកជននានាទៅតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ។

ឃ-កំណត់ស្ដង់ដាស្ថិតិជាតិដែលទាក់ទងនឹងចំណាត់ថ្នាក់ ទស្សនាទាននិយមន័យ និងអង្គពិនិត្យពិចារណាស្ថិតិ ដើម្បីចៀសវាងការភាន់ច្រឡំពីសំណាក់អ្នកប្រើប្រាស់ទិន្នន័យ និងការជាន់គ្នាក្នុងការផលិតទិន្នន័យស្ថិតិផ្លូវការ ។

### មាត្រា ១៦.-

ក្រុមប្រឹក្សាស្ថិតិ ត្រូវបានបង្កើតឡើងដើម្បីផ្ដល់ប្រឹក្សាជូនក្រសួងផែនការ ក្នុងការជំរុញកិច្ចអភិវឌ្ឍប្រព័ន្ធស្ថិតិជាតិ ។

សមាសភាព តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាស្ថិតិ ត្រូវកំណត់ដោយអនុក្រឹត្យ ។

### មាត្រា ១៧.-

គណៈកម្មាធិការសម្របសម្រួលស្ថិតិ ត្រូវបានបង្កើតឡើងដើម្បីជួយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួង

ផែនការ ក្នុងការសម្របសម្រួលផ្នែកបច្ចេកទេសស្ថិតិផ្លូវការរបស់រាជរដ្ឋាភិបាល ។

សមាសភាព តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការសម្របសម្រួលស្ថិតិត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៨.-**

បណ្តាក្រសួង ស្ថាប័នរាជរដ្ឋាភិបាលដែលត្រូវផលិតស្ថិតិផ្លូវការក្នុងច្បាប់នេះ ត្រូវបង្កើតអង្គភាពស្ថិតិនៅក្នុងរចនាសម្ព័ន្ធរបស់ខ្លួន សម្រាប់បម្រើឲ្យគោលដៅស្ថិតិ ហើយត្រូវផ្ញើទិន្នន័យស្ថិតិដែលផលិតបានមកវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ។

**មាត្រា ១៩.-**

អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ ជាប្រធានមន្ត្រីស្ថិតិនៃព្រះរាជាណាចក្រកម្ពុជា ហើយត្រូវទទួលខុសត្រូវក្នុងការធានាថាស្ថិតិត្រូវបានផលិត អភិវឌ្ឍ និងផ្សព្វផ្សាយដោយឯករាជ្យ ប្រកបដោយវិជ្ជាជីវៈនិងទាន់ពេលវេលា ។

## ជំពូកទី ៥
## ប្រភពធនធានហិរញ្ញវត្ថុ

**មាត្រា ២០.-**

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ត្រូវរៀបចំថវិកាចំណាយប្រចាំឆ្នាំសម្រាប់ដំណើរការផលិត និងផ្សព្វផ្សាយទិន្នន័យស្ថិតិ ដោយដាក់សុំការសម្រេចក្នុងអង្គប្រជុំក្រុមប្រឹក្សាស្ថិតិមុននឹងបញ្ចូលក្នុងកញ្ចប់ថវិការបស់ក្រសួងផែនការ ។

**មាត្រា ២១.-**

អង្គភាពស្ថិតិនៃបណ្តាក្រសួងនិងស្ថាប័នរាជរដ្ឋាភិបាល ត្រូវរៀបចំផែនការសកម្មភាពអំពីការងារស្ថិតិរបស់ខ្លួន ទៅតាមអាទិភាពនិងភាពចាំបាច់នៃតម្រូវការស្ថិតិ រួចត្រូវរៀបចំផែនការថវិកាចំណាយប្រចាំឆ្នាំបញ្ចូលទៅក្នុងគម្រោងថវិកាក្រសួងសាមី ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងហិរញ្ញវត្ថុសាធារណៈជាធរមាន ដើម្បីទទួលបានថវិកាគាំទ្រគ្រប់គ្រាន់ សម្រាប់ដំណើរការការងារប្រចាំឆ្នាំរបស់អង្គភាព និងធានាបាននូវនិរន្តរភាពស្ថិតិ ។

**មាត្រា ២២.-**

ធនធានហិរញ្ញវត្ថុនៃវិទ្យាស្ថានជាតិស្ថិតិបានមកពី ៖

ក-កញ្ចប់ថវិការបស់ក្រសួងផែនការ ។

ខ-ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ ។

គ-អំណោយពីសប្បុរសជននានា ។

ឃ-ប្រភពធនធានស្របច្បាប់ផ្សេងៗ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL ក្រសួងព្រះបរមរាជវាំង

# ជំពូកទី ៦
## ការបោះពុម្ព និងផ្សព្វផ្សាយ

**មាត្រា ២៣.-**

ដើម្បីបម្រើឲ្យសំណូមពរស្ថិតិរបស់អ្នកប្រើប្រាស់ ៖

ក-វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ក៏ដូចជាអង្គភាពស្ថិតិនៃក្រសួងស្ថាប័នផ្សេងៗទៀតរបស់រាជរដ្ឋាភិបាលត្រូវបោះពុម្ព និងផ្សព្វផ្សាយទិន្នន័យស្ថិតិដែលបានផលិតជូនអ្នកប្រើប្រាស់ទាំងអស់ ។

ខ-វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ត្រូវបោះពុម្ពព្រឹត្តិបត្រស្ថិតិប្រចាំឆ្នាំដែលគ្របដណ្តប់ទិដ្ឋភាពសំខាន់ៗនៃលក្ខខណ្ឌសេដ្ឋកិច្ច សង្គមកិច្ចរបស់ប្រទេស ។

គ-វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ត្រូវរក្សាឃ្លាំងទិន្នន័យទាំងឡាយដែលមានទិន្នន័យផ្ទុំអាចឲ្យសាធារណជនទូទៅរកបានតាមប្រព័ន្ធអ៊ិនធឺណិត ។

**មាត្រា ២៤.-**

រាល់ទិន្នន័យស្ថិតិដែលប្រកាសផ្សាយ ដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ គឺជាស្ថិតិផ្លូវការដែលបានចាត់តាំង ដោយរាជរដ្ឋាភិបាល ។

**មាត្រា ២៥.-**

ទិន្នន័យផ្ទុំដែលមានត្រូវតែជាទិន្នន័យសំខាន់ ត្រឹមត្រូវ គួរជឿទុកចិត្តបាន ទាន់ពេលវេលា ស៊ីចង្វាក់គ្នាអាចប្រៀបធៀបបានហើយងាយស្រួលរកបានដោយអ្នកប្រើប្រាស់ ។

**មាត្រា ២៦.-**

គ្រប់ទិន្នន័យស្ថិតិត្រូវតែបង្ហាញក្នុងទម្រង់ច្បាស់លាស់ ងាយយល់ ផ្សព្វផ្សាយតាមរបៀបសមស្របទាន់ពេល ងាយស្រួលរកយកមកប្រើប្រាស់បាន ដោយផ្អែកលើគោលការណ៍មិនលំអៀងជាមួយនឹងការគាំទ្រមេតាទិន្នន័យ និងការណែនាំ ។

ប្រតិទិនផ្សព្វផ្សាយនូវសូចនាករសំខាន់ៗត្រូវធ្វើជាសាធារណៈ។

**មាត្រា ២៧.-**

ភាពទទួលបានមីក្រូទិន្នន័យត្រូវអនុញ្ញាតឲ្យផ្តល់សម្រាប់តែគោលបំណងស្រាវជ្រាវ ក្រោមលក្ខខណ្ឌដោយមិនឲ្យដឹងពីអត្តសញ្ញាណនៃព័ត៌មានបុគ្គល ក្រុមហ៊ុន សហគ្រាស និងស្ថាប័ន ។

ភាពទទួលបានមីក្រូទិន្នន័យ សម្រាប់តម្រូវការប្រើប្រាស់ក្នុងករណីពិសេស ត្រូវកំណត់តាមវិធានបែបបទដោយឡែក ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងផែនការ ។

**មាត្រា ២៨.-**

អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិត្រូវបានប្រគល់សិទ្ធិក្នុងការធ្វើអត្ថាធិប្បាយ ពន្យល់កែតម្រូវលើ

ការបកស្រាយមិនត្រឹមត្រូវ និងការប្រើប្រាស់ស្ថិតិខុស ទោះជាជននោះ ឬស្ថាប័ននោះជាម្ចាស់ដើមនៃស្ថិតិនោះក៏ដោយ ។

## ជំពូកទី ៧
## សិទ្ធិ និងភារកិច្ច

### មាត្រា ២៩.-

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការនិងអង្គភាពស្ថិតិ តាមបណ្តាក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ត្រូវបានអនុញ្ញាតឲ្យដំណើរការសកម្មភាពស្ថិតិនានា ដើម្បីទទួលបាននូវព័ត៌មានស្ថិតិពីអ្នកឆ្លើយ សម្រាប់ផលិតស្ថិតិផ្លូវការ ដោយយោងតាមមាត្រា ១២ និងមាត្រា ១៣ នៃច្បាប់នេះ ។

### មាត្រា ៣០.-

មន្ត្រីរាជការ បុគ្គលិកធ្វើការនៅវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការនិងអង្គភាពស្ថិតិក្នុងក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ក៏ដូចជាមន្ត្រីស្ថិតិដែលត្រូវបានចាត់តាំងដោយអង្គការទាំងនោះនៅពេលបម្រើការងារ ឬបំពេញភារកិច្ចក្រោមច្បាប់នេះ ត្រូវធានារក្សាការសម្ងាត់នូវរាល់ព័ត៌មានបុគ្គលទាំងឡាយ ដែលបានមកពីអ្នកឆ្លើយ ។ ព័ត៌មានដែលប្រមូលបានក្រោមច្បាប់នេះ ត្រូវយកមកប្រើប្រាស់តែក្នុងគោលដៅស្ថិតិប៉ុណ្ណោះ ។

### មាត្រា ៣១.-

មន្ត្រីរាជការនិងមន្ត្រីស្ថិតិដែលត្រូវបានចាត់តាំងដោយក្រសួងផែនការ និងមន្ត្រីស្ថិតិដែលត្រូវបានចាត់តាំងដោយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលមានសិទ្ធិចេញចូលក្នុងទីកន្លែងដោយមានវត្តមានអ្នកកាន់កាប់ទីកន្លែងក្នុងគោលដៅប្រមូលទិន្នន័យស្ថិតិ ។

ទីកន្លែងរួមមាន ផ្ទះសំបែង ឬផ្នែកនៃទីបរិវេណផ្សេងទៀតដែលមានមនុស្សស្នាក់នៅដាច់ដោយឡែក និងទីកន្លែងផ្សេងទៀត ។

### មាត្រា ៣២.-

មន្ត្រីរាជការនិងមន្ត្រីស្ថិតិដែលត្រូវបានចាត់តាំងដោយក្រសួងផែនការ និងមន្ត្រីស្ថិតិដែលត្រូវបានចាត់តាំងដោយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលត្រូវបង្ហាញលិខិតបញ្ជាបេសកកម្មរបស់ខ្លួន និងអត្តសញ្ញាណបណ្ណផ្លូវការជូនអ្នកឆ្លើយ ហើយត្រូវប្រកាន់អាកប្បកិរិយាសុភាពរាបសា និងវិជ្ជាជីវៈ ក្នុងការសាកសួរព័ត៌មានឲ្យបានសមស្របទៅតាមទំនៀមទម្លាប់មូលដ្ឋាន និងសណ្តាប់ធ្នាប់សាធារណៈ ។

មុខសញ្ញាទីកន្លែង ពេលវេលាចេញចូលទីកន្លែង ត្រូវតែសមស្របទៅនឹងបេសកកម្មដែលបានកំណត់ ។

**មាត្រា ៣៣.-**

អ្នកឆ្លើយទាំងឡាយត្រូវផ្តល់ព័ត៌មានត្រឹមត្រូវ គ្រប់គ្រាន់ និងទាន់ពេលវេលាជូនមន្ត្រីស្ថិតិដែលត្រូវបានចាត់តាំងដោយក្រសួងផែនការនិងបណ្តាក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ។

## ជំពូកទី ៨
## ទោសប្បញ្ញត្តិ

**មាត្រា ៣៤.-**

មន្ត្រីរាជការ និងមន្ត្រីស្ថិតិដែលត្រូវបានចាត់តាំងដោយក្រសួងផែនការ និងមន្ត្រីស្ថិតិដែលត្រូវបានចាត់តាំងដោយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៣០ មាត្រា ៣១ ឬមាត្រា ៣២ នៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មរដ្ឋបាល ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ។

**មាត្រា ៣៥.-**

បុគ្គលឬមេគ្រួសារដែលប្រព្រឹត្តល្មើសនឹងមាត្រា ៣៣ នៃច្បាប់នេះ ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរដោយវិទ្យាស្ថានជាតិស្ថិតិ ។

ក្នុងករណីដែលបានទទួលរងនូវការព្រមានដូចមានចែងក្នុងកថាខណ្ឌខាងលើហើយ ហើយនៅតែប្រព្រឹត្តល្មើសម្តងទៀតត្រូវពិន័យជាប្រាក់ពី ១០ ០០០ (មួយម៉ឺន) រៀល ទៅ ៥០ ០០០ (ប្រាំម៉ឺន) រៀល ។

និយោជក ឬអ្នកទទួលខុសត្រូវក្នុងក្រុមហ៊ុន ឬសហគ្រាស ឬអង្គការផ្សេងទៀតដែលប្រព្រឹត្តល្មើសនឹងមាត្រា ៣៣ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ៥ ០០០ ០០០ (ប្រាំលាន) រៀល ទៅ ១០ ០០០ ០០០( ដប់លាន) រៀល ។

**មាត្រា ៣៦.-**

បុគ្គលរារាំងដោយចេតនានូវដំណើរការប្រមូលទិន្នន័យស្ថិតិ ដោយមន្ត្រីស្ថិតិដែលត្រូវបានចាត់តាំងដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ឬមន្ត្រីស្ថិតិដែលត្រូវបានចាត់តាំងដោយក្រសួង ស្ថាប័នរាជរដ្ឋាភិបាលតាមច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ថ្ងៃ ទៅ ១ (មួយ) ខែ និងពិន័យជាប្រាក់ពី ១០ ០០០ (មួយម៉ឺន) រៀល ទៅ ១០០ ០០០ (មួយសែន) រៀល ។

## ជំពូកទី ៩
## អន្តរប្បញ្ញត្តិ

**មាត្រា ៣៧.-**

រាល់លិខិតបទដ្ឋានគតិយុត្តដែលបានបង្កើតឡើងដើម្បីអនុវត្តច្បាប់ស្តីពីស្ថិតិ ដែលបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៥ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ត្រូវនៅមានអានុភាពអនុវត្តតទៅទៀតរហូតមានអត្ថបទថ្មីមកកែប្រែឬលុបចោល លើកលែងតែបទប្បញ្ញត្តិ ដែលផ្ទុយនឹងស្មារតីនៃច្បាប់នេះ ។

## ជំពូកទី ១០
## អវសានប្បញ្ញត្តិ

**មាត្រា ៣៨.-**

ច្បាប់ស្តីពីស្ថិតិដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៥ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ត្រូវទុកជានិរាករណ៍ ហើយត្រូវជំនួសដោយច្បាប់នេះ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០១៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៧. ១៥១២. ១១៥៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

**ហត្ថលេខា**

**ឆាយ ថន**

លេខៈ ១១៦០ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ,ថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ២០១៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

នស/រកត/១២១៥/ ១១៤៧

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១** : តែងតាំងលោកជំទាវ **នោម សោភ័ណ្ឌី** ជាទីប្រឹក្សាផ្ទាល់សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ដោយ មិនយកប្រាក់បៀវត្ស ។

**មាត្រា២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧. ១៥០៤. ១១៦៦

លេខ:១១៧៧/ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៥*

# ព្រះរាជក្រឹត្យ

នស/រកត/១២១៥/ ១១៨៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម ចំនួន០២រូប ជាទីប្រឹក្សាសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ៖

១-ឯកឧត្តម **ចាន់ ជា** មានឋានៈស្មើ រដ្ឋលេខាធិការ ដោយពុំទទួលយកប្រាក់បៀវត្ស

២-ឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ី ទ្រូ** អត្តលេខ ០៦៨៨ មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ដោយពុំទទួលយកប្រាក់បៀវត្ស។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរជ. ១៥១២ - ១១៦៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៥*

លេខ: ១១៧៦ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១២១៥/១១៥០

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
-បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១**: តែងតាំង និងផ្ដល់ឋានៈជាជំនួយការ**សម្ដេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចំនួន ០២រូប មានឋានៈស្មើ អគ្គនាយក ដោយមិនយកប្រាក់បៀវត្សៈ

១- ឯកឧត្ដម **គិន សុជាតិ**
២- ឯកឧត្ដម **ជា ហៃ**

**មាត្រា ២**: សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧. ១៥១៤. ១១៦៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៥*

លេខៈ ១១៧៩ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១២១៥/ ១១៥១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** :តែងតាំង និងផ្តល់ឋានៈជាទីប្រឹក្សា ជំនួយការ**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចំនួន ០២រូប:

១-ឯកឧត្តម **ប៉ោ ទ្រី ខឿន** ទីប្រឹក្សា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ដោយមិនយកប្រាក់បៀវត្ស

២-ឯកឧត្តម **ហាក់ ចាន់នី** ជំនួយការ មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ដោយមិនយកប្រាក់បៀវត្ស ។

**មាត្រា ២** :សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧. ១៥១៤. ១១៦៩

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១៥*

លេខៈ ១១៨០ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១២១៥/១១៥៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃ ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តម្លើងឋានន្តរស័ក្តិ ជាករណីពិសេស ដល់ឯកឧត្តម **ហ៊ូ ណារ៉ុធ** ពីវរមន្ត្រី ថ្នាក់លេខ៤ មកឧត្តមមន្ត្រី ថ្នាក់លេខ៤ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ការ. ១៥១៤. ១១៧០

លេខ:១១៩១ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៥*

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១២១៥/១១៥៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃ ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តម្លើងថ្នាក់ ជាករណីពិសេស ដល់លោក **ខឹម សុខខុន** ពីឧត្តមមន្ត្រី ថ្នាក់លេខ៣ មកឧត្តមមន្ត្រី ថ្នាក់លេខ១ ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧. ១៥១២. ១១៧១

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៥*

លេខ: ១១៩៧ ស.ណ
**សំណៅចំលងមានគម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១២១៥/១១៥៨

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្ទេរក្របខ័ណ្ឌលោក **យ៉ែម ច័ន្ទណារ៉ុ** ពីឋានន្តរសក្តិវរមន្ត្រីថ្នាក់លេខ៣ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ មកក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ក្រសួងមហាផ្ទៃ ។

**មាត្រា២ :** តែងតាំងឋានន្តរសក្តិ **ឧត្តមសេនីយ៍ទោ** ដល់លោក **យ៉ែម ច័ន្ទណារ៉ុ** អត្តលេខ ៧៧៨៦៦ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា៣ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៩៧.១៥០១៤-១១៧៤

លេខ ១១៩៧ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៥*

សយ សុខា

នស/រកត/១២១៥/១១៥៦

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ និងនាយនគរបាលជាន់ខ្ពស់ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

**ក- ឋានន្តរស័ក្តិ ឧត្តមសេនីយ៍ឯក :**

១- ឧត្តមសេនីយ៍ទោ **ឆយ ឈឿង** អត្តលេខ ០៨០៧
២- ឧត្តមសេនីយ៍ទោ **ឡូន ចិន្តាស័ក** អត្តលេខ ០៨៥៧
៣- ឧត្តមសេនីយ៍ទោ **កែវ ឡាដា** អត្តលេខ ០៨០៥
៤- ឧត្តមសេនីយ៍ទោ **គ្រី គឹមសេង** អត្តលេខ ០៧៩៧ ។

**ខ- ឋានន្តរស័ក្តិ ឧត្តមសេនីយ៍ទោ :**

១- ឧត្តមសេនីយ៍ត្រី **ហេង សាវ៉ាត់** អត្តលេខ ០៥៥៤
២- ឧត្តមសេនីយ៍ត្រី **កែន សុធន** អត្តលេខ ៥៣៧៩៥
៣- ឧត្តមសេនីយ៍ត្រី **ហែម សំអុន** អត្តលេខ ០៤៩០៥
៤- ឧត្តមសេនីយ៍ត្រី **កែ សុវណ្ណៈ** អត្តលេខ ២០៤៦១
៥- ឧត្តមសេនីយ៍ត្រី **កែវ មុនីរ័ត្ន** អត្តលេខ ០៥៨៣៧ ។

ROYAUME DU CAMBODGE • MINISTÈRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង

**គ- ឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី :**

១- វរសេនីយ៍ឯក **យ៉ែម សារ៉ាវុធ** អត្តលេខ ២០៤៧២
២- វរសេនីយ៍ឯក **ចេង បុញ្ញរិទ្ធ** អត្តលេខ ០៥៨៣៤
៣- វរសេនីយ៍ឯក **អែល ឈាន** អត្តលេខ ០១៧៥៧
៤- វរសេនីយ៍ឯក **ហុង រតនៈ** អត្តលេខ ៥៧៩៩៦
៥- វរសេនីយ៍ឯក **ឈី ជាង** អត្តលេខ ៦២៤៨៤
៦- វរសេនីយ៍ឯក **ឆ្លួន ម៉ុន្នី** អត្តលេខ ៦២៥៣១
៧- វរសេនីយ៍ឯក **ស្វាយ ស៊ីថា** អត្តលេខ ៥៨០៤៣
៨- វរសេនីយ៍ឯក **ឧង សុខា** អត្តលេខ ៦១៩៩២
៩- វរសេនីយ៍ឯក **សុខ ណារ៉ុង** អត្តលេខ ៣៦៩៧៧
១០- វរសេនីយ៍ឯក **ឆ្នូក ឡា** អត្តលេខ ០៥៦២១ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកត.១២១៥.១១៧៦

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៥

លេខ:១២០៣ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

សយ សុខា

នស/រកត/១២១៥/ ១១៥៩

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ត្រី** ដល់នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ០៣រូប៖

១- វរសេនីយ៍ឯក **យិន តារ** អត្តលេខ ០១០២៦

២- វរសេនីយ៍ឯក **សុខ ណុប** អត្តលេខ ០៦០៦៤

៣- វរសេនីយ៍ឯក **ជា រិទ្ធី** អត្តលេខ ៥៥៩៧២ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

រ.ល.ក. ១៥១២.១១៧៦

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៥

លេខ: ១២០០ ស.ណ
សំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០១៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/១២១៥/ ១១៥៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈ ដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិដល់ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ និងនាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

**ក- ឧត្តមសេនីយ៍ទោ ៖**

- លោកឧត្តមសេនីយ៍ត្រី **មាស ម៉ាន់ថុន** អត្តលេខ ០២១៣៩

**ខ- ឧត្តមសេនីយ៍ត្រី ៖**

-លោកវរសេនីយ៍ឯក **ជាក សុភាព** អត្តលេខ ៥៦៤៧០ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

លេខៈ ៦៧០១ ស.ណ
**សំណៅចំលងមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុយ សុខា**

រកម. ១៥១៤. ១១៧៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៥*

# ព្រះរាជក្រឹត្យ

## យើង

នស/រកត/១២១៥/១១៦០

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ហោរភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តាំងស៊ប់ក្នុងក្របខ័ណ្ឌដល់មន្ត្រីរាជការ ២០ រូប ទៅក្នុងឋានន្តរស័ក្តិគ្រូបង្រៀនកម្រិតឧត្តម នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងឋានន្តរស័ក្តិអនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងអប់រំ យុវជន និងកីឡា ៖

- តាំងស៊ប់ចាប់ពីថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១៥

| | | |
|---|---|---|
| ១- | លោកស្រី គីម ផល្លា | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៣ |
| ២- | លោក ច័ន្ទ សុមាលា | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៤ |
| ៣- | លោក អ៊ូច និមល | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៤ |

| | | |
|---|---|---|
| ៤- | លោក ប៉ាន់ យ៉ាត | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៤ |
| ៥- | លោក មិត វៅ | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៤ |
| ៦- | លោកស្រី ឃុយ សម្ផស្ស | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៤ |
| ៧- | លោកស្រី វួន សុផា | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៤ |
| ៨- | លោក មាន សុធី | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៤ |
| ៩- | លោក ហ៊ិន ទូច | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៣ |
| ១០- | លោក វង វុទ្ធី | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៣ |
| ១១- | លោក ឡឹក ស៊ីនរិទ្ធី | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៣ |
| ១២- | លោកស្រី ញាណ ភក្ដកញ្ញា | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៤ |
| ១៣- | លោក សឿ សៅរិន | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៤ |
| ១៤- | លោក សួន វិសាល | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៤ |
| ១៥- | លោកស្រី យ៉ុម សារឿន | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៤ |
| ១៦- | លោក សឿន សារ៉ាត | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៤ |
| ១៧- | លោកស្រី យ៉ា ថាវី | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៤ |

- តាំងស៊ីប់ចាប់ពីថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៥

| | | |
|---|---|---|
| ១៨- | លោក ប៊ុង រេងគុណ | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៤ |

- តាំងស៊ីប់ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៦

| | | |
|---|---|---|
| ១៩- | លោក មាស សុភា | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៣ |

- តាំងស៊ីប់ចាប់ពីថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៦

| | | |
|---|---|---|
| ២០- | លោកស្រី សេង ហ្សានីន | អនុមន្ត្រី ថ្នាក់លេខ ១ |

**មាត្រា ២ :** សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកត.១២១៥.១១៧៩

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៥*

លេខៈ ១២០២ ស.ណ

សំណៅដែលមានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

២/២

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/១២១៥/ ១១៦១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ ចំនួន ១៦រូប ទៅក្នុងឋានន្តរស័ក្តិ មន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ចាប់ពីថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៥ :

| | | | |
|---|---|---|---|
| ១. លោក | **ប្រាក់ ឧត្តម** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | ថ្នាក់លេខ ៣ |
| ២. លោកស្រី | **ឃួន សុជាតា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | ថ្នាក់លេខ ៤ |
| ៣. លោក | **អ៊ុំ ឧិត្យវណ្ណាវិចិត្រ** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | ថ្នាក់លេខ ៤ |
| ៤. លោកស្រី | **ជុំ ស្រីរ័ត្ន** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | ថ្នាក់លេខ ៤ |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង

| | | | |
|---|---|---|---|
| ៥. លោកស្រី | **ឆិល លីដា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | ថ្នាក់លេខ ៤ |
| ៦. លោកស្រី | **ខន្យ តារាសុភ័ក្រ** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | ថ្នាក់លេខ ៤ |
| ៧. លោក | **ទ្រី សុខហេង** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | ថ្នាក់លេខ ៤ |
| ៨. លោក | **វ៉ាង ឧត្តរា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | ថ្នាក់លេខ ៤ |
| ៩. លោក | **ឆៀម សែត** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | ថ្នាក់លេខ ៤ |
| ១០. លោក | **សាក់ ម៉ាលីន** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | ថ្នាក់លេខ ៤ |
| ១១. លោកស្រី | **មួង សុខធីតា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | ថ្នាក់លេខ ៤ |
| ១២. លោកស្រី | **ឡុត គីមហៀក** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | ថ្នាក់លេខ ៤ |
| ១៣. លោកស្រី | **ឡុង លីដែន** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | ថ្នាក់លេខ ៤ |
| ១៤. លោក | **ហ៊ីន ច័ន្ទកុសល** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | ថ្នាក់លេខ ៤ |
| ១៥. លោកស្រី | **គោគ ច័ន្ទម៉ានី** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | ថ្នាក់លេខ ៤ |
| ១៦. លោកស្រី | **ស្រៀន គីមឌួច** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | ថ្នាក់លេខ ៤។ |

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុក អនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកត.១២១៥.១១៧៩

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១៥*

លេខ:១២០៤ស.ណ

**សំណៅចំលងមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១២១៥/១១៦៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

**ប្រោសព្រះរាជទាន**

**នូវ**

**គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍**

ចំពោះ

លោក Huang Xinglong

៣៧.១៥០៤.១១៧០

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៥*

លេខ:១១៧៦ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែ ធ្នូ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១៧១ អនក្រ.បក**

**អនុក្រឹត្យ**

**ស្តីពី**

**ការដាក់ឱ្យអនុវត្តកម្មវិធីកាត់បន្ថយនិង/ឬលុបបំបាត់ពន្ធគយរបស់ព្រះរាជាណាចក្រកម្ពុជា ស្របតាមនាមវលីនៃតារាងពន្ធគយសុខដុមរបស់អាស៊ាន ឆ្នាំ២០១២ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០៤/០០២ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារនៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជា ក្នុងអង្គការពាណិជ្ជកម្មពិភពលោក
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៧ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៣/០០៤ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាស្តីពីការបង្កើតក្រុមប្រឹក្សាសហប្រតិបត្តិការគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៣/០០១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាស្តីពីការធ្វើឱ្យស៊ីចង្វាក់គ្នានៃការកំណត់មុខទំនិញនិងប្រព័ន្ធលេខកូដ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**មាត្រា១.-**

| KH | 0505.10.90 | - - Other | 15 | Schedule A-IL | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| | 0505.90 | - Other: | | | | | | | | | | | | | |
| KH | 0505.90.10 | - - Duck feathers | 15 | Schedule A-IL | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| KH | 0505.90.90 | - - Other | 15 | Schedule A-IL | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| | 05.06 | Bones and horn-cores, unworked, defatted, simply prepared (but not cut to shape), treated with acid or degelatinised; powder and waste of these products. | | | | | | | | | | | | | |
| KH | 0506.10.00 | - Ossein and bones treated with acid | 15 | Schedule A-IL | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| KH | 0506.90.00 | - Other | 15 | Schedule A-IL | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| | 05.07 | Ivory, tortoise-shell, whalebone and whalebone hair, horns, antlers, hooves, nails, claws and beaks, unworked or simply prepared but not cut to shape; powder and waste of these products. | | | | | | | | | | | | | |
| | 0507.10 | - Ivory; ivory powder and waste: | | | | | | | | | | | | | |
| KH | 0507.10.10 | - - Rhinoceros horns; ivory powder and waste | 15 | Schedule A-IL | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| KH | 0507.10.90 | - - Other | 15 | Schedule A-IL | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| | 0507.90 | - Other: | | | | | | | | | | | | | |
| KH | 0507.90.10 | - - Horns, antlers, hooves, nails, claws and beaks | 15 | Schedule A-IL | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| KH | 0507.90.20 | - - Tortoise-shell | 15 | Schedule A-IL | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| KH | 0507.90.90 | - - Other | 15 | Schedule A-IL | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| | 0508.00 | Coral and similar materials, unworked or simply prepared but not otherwise worked; shells of molluscs, crustaceans or echinoderms and cuttle-bone, unworked or simply prepared but not cut to shape, powder and waste thereof. | | | | | | | | | | | | | |
| KH | 0508.00.10 | - Coral and similar materials | 15 | Schedule A-IL | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| KH | 0508.00.20 | - Shells of molluscs, crustaceans or echinoderms | 15 | Schedule A-IL | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| KH | 0508.00.90 | - Other | 15 | Schedule A-IL | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |



តទៅរាជកិច្ចលេខ ២

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ១៩៤ អនក្រ.បក**

## អនុក្រឹត្យ

## ស្ដីពីការផ្ទេរឥណទានថវិកា

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៣៣៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ស្ដីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១.**_

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាពីជំពូក ៦២ (អត្ថប្រយោជន៍សង្គម) ពីមន្ទីរអប់រំ យុវជន និងកីឡា ១៨ រាជធានី ខេត្ត មកជំពូក ៦០ (ការទិញ) ចំនួន ៥ ៥២៣ ០០០ ០០០រៀល (ផ្នែកអប់រំ) ជូនក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការ គ្រប់គ្រងឆ្នាំ២០១៥ ។

មាត្រា២._

ការបែងចែកឥណទានថវិកាផ្ទេរក្នុងជំពូកនេះ តាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបំពេញតម្រូវការចំណាយជាក់ស្តែងរបស់ក្រសួងអប់រំ យុវជន និងកីឡាសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ។

**មាត្រា៣.**_

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា និងមន្ទីរអប់រំ យុវជន និងកីឡា ១៨ រាជធានី ខេត្តត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញថ្ងៃទី ៣១ ខែ ៨ ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ១៩៥ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ ៤៨៨អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៣៦អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**មាត្រា១._**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ២៣ ៧០០ ០០០ ០០០ រៀល (ម្ភៃបីប៊ីលានប្រាំពីររយលានរៀលគត់) ពីជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ៦១ (សេវាកម្ម) ចំនួន ៣ ៧០០លានរៀល និងជំពូក ៦២ (អត្ថប្រយោជន៍សង្គម) ចំនួន ២០ ០០០លានរៀល ជូនទីស្តីការគណៈរដ្ឋមន្ត្រី សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥។

**មាត្រា២._**

ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកទាំងនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ទូទាត់ចំណាយសោហ៊ុយបេសកកម្មក្រៅប្រទេសចំនួន ៣ ៧០០លានរៀល និងបញ្ចប់ការទូទាត់ចំណាយទិញទំនិញពិសេសពីសាធារណរដ្ឋកាហ្សាគស្ថាំងចំនួន ២០ ០០០លានរៀល។

**មាត្រា៣._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ១៩៦ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការផ្ទេរឥណទានថវិកា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ ៤៨៨អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៣៦អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

<u>**សម្រេច**</u>

**មាត្រា១._**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ១៣០ ០០០ ០០០ រៀល (មួយរយសាមសិបលានរៀលគត់) ពីជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ៦២ (អត្ថប្រយោជន៍សង្គម) ជូនទីស្តីការគណៈរដ្ឋមន្ត្រី សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥។

**មាត្រា២._**

ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ទូទាត់ចំណាយធ្វើបុណ្យសពនាយទាហានថ្នាក់ឧត្តមសេនីយ៍របស់ក្រសួងការពារជាតិចំនួន ០៣ រូប។

**មាត្រា៣._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: [illegible]

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ផ្ទេរភារកិច្ចលោក **ពេជ សុធា** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៤ ពីអភិបាលស្រុកសន្ទុក ឲ្យទៅបម្រើការងារនៅសាលាខេត្តកំពង់ធំ។

**មាត្រា ២ :** តែងតាំងលោក **យស បញ្ញារិទ្ធ** ឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ១ ឲ្យទៅកាន់មុខតំណែងជាអភិបាលស្រុកសន្ទុក នៃខេត្តកំពង់ធំ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ និងមាត្រា២ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១២៣៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន គ.ជ.អ.ប
- បានឃើញអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា៧ មាត្រា៨ មាត្រា១២ មាត្រា១៣ មាត្រា១៥ មាត្រា១៦ និងមាត្រា១៧នៃអនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន គ.ជ.អ.ប
- យោងតាមសំណើរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប)។

## សម្រេច

**មាត្រា ១.-**

ត្រូវបានតែងតាំងមន្ត្រីរាជការចំនួន០២រូប ក្នុងរចនាសម្ព័ន្ធនៃលេខាធិការដ្ឋាន គ.ជ.អ.ប ដូចមានរាយនាមខាងក្រោម៖

១. លោក **សុខ សុទ្ធី** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៣ នៃក្របខណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ជា**ប្រធានអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ** នៃលេខាធិការដ្ឋាន គ.ជ.អ.ប។

២. លោក **ឡុង ទិសិដ្ឋ** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៣ នៃក្របខណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ជា**អនុប្រធានអង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី** នៃលេខាធិការដ្ឋាន គ.ជ.អ.ប។

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធាន គ.ជ.អ.ប រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ០១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.–**

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងផ្តល់ជូនសប្បុរសជនចំនួន ១៨ រូបដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងឧបដ្ឋានសាលា កុដិ ជួសជុលផ្លូវថ្នល់ និងចាក់សាបបំពេញ ក្នុងទីធ្លាវត្ត នៅ**វត្តស្វាយបទុម** ស្ថិតនៅក្នុងឃុំស្វាយអន្ទរ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម ៖

**ក. មេដាយមាសស្ថាបនាជាតិចំនួន ០៧ គ្រឿង ផ្តល់ជូន ៖**

| | | |
|---|---|---|
| ១-ឧបាសិកា **កេត ហាប** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន ១២.០៩៥ ដុល្លារ |
| ២-ឧបាសក **សាន់ សាន** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន ១១.៩២០ ដុល្លារ |
| ៣-ឧបាសិកា **ជា ពិន** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន ១១.៥០០ ដុល្លារ |
| ៤-ឧបាសិកា **គីម ទូចហួ** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន ១១.៥០០ ដុល្លារ |
| ៥-ឧបាសក **អ៊ុន យ៉ឺន** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន ១១.២០០ ដុល្លារ |
| ៦-លោក **ម៉េង វ៉ាន់ឌី** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១១.០៥០ ដុល្លារ |
| ៧-ឧបាសក **ញ៉ឹម អ៊ីន់** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន ១០.៥០០ ដុល្លារ |

**ខ. មេដាយប្រាក់ស្ថាបនាជាតិចំនួន ០៤ គ្រឿង ប្រគេន និងផ្តល់ជូន :**

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ **លន់ លាត** | លេខាអនុគណវត្តស្វាយបទុម | បច្ច័យចំនួន | ៥.៣៥០ ដុល្លារ |
| ២-ឧបាសិកា **ណាំ ច្រិច** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន | ៥.២៥០ ដុល្លារ |
| ៣-ឧបាសក **បូទ ឆុន** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន | ៥.២០០ ដុល្លារ |
| ៤-ឧបាសក **ទាំង ម៉ុត** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន | ៥.២០០ ដុល្លារ |

**គ. មេដាយសំរិទ្ធិស្ថាបនាជាតិចំនួន ០៧ គ្រឿង ផ្តល់ជូន :**

| | | | |
|---|---|---|---|
| ១-ឧបាសិកា **ជិន ផៃ** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន | ១.៩៩៩ ដុល្លារ |
| ២-លោកស្រី **សុខ អាំ** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន | ១.៣៨២ ដុល្លារ |
| ៣-លោក **លឹម ម៉េងហុង** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន | ១.៣៣៥ ដុល្លារ |
| ៤-លោក **ថេង ណេង** | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន | ១.៣១០ ដុល្លារ |
| ៥-ឧបាសក **ប្រាក់ ប៊ុន** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន | ១.១៣២ ដុល្លារ |
| ៦-ឧបាសិកា **សេង សូទ** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន | ១.០៩៦ ដុល្លារ |
| ៧-ឧបាសិកា **សៀវ ហួយ** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន | ១.០៩០ ដុល្លារ |

មាត្រា ២ . –

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ: ០៧ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ ._**

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ផ្តល់ជូនសប្បុរសជនចំនួន ០២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង ឧបដ្ឋានសាលា កុដិ ជួសជុលផ្លូវថ្នល់ និងចាក់សាបបំពេញ ក្នុងទីធ្លាវត្ត នៅ**វត្តស្វាយបទុម** ស្ថិតនៅក្នុងឃុំស្វាយអន្ទរ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង ដែលមានរាយនាមដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១-លោក | **ភួង សុខឃឿន** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន ៣៥.០០០ ដុល្លារ |
| ២-ឧបាសក | **ឈន ឆេង** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន ៣៤.០០០ ដុល្លារ |

**មាត្រា ២ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ០៣ អនុក្រ.ចស

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

មាត្រា ១.–

ត្រូវបានបំពាក់**មេដាយមាសស្ថាបនាជាតិ** ប្រគេន និងផ្តល់ជូនសប្បុរសជនចំនួន ២៣រូប ដែលបានបរិច្ចាគ ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានានៅក្នុងវិស័យ ព្រះពុទ្ធសាសនា និងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ នៅ**វត្តអារញ្ញសាគរ** ស្ថិតនៅក្នុងសង្កាត់សៀមរាប ក្រុងសៀមរាប ខេត្តសៀមរាប ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

**ក. មេដាយមាសស្ថាបនាជាតិចំនួន ០៥ គ្រឿង ផ្តល់ជូន :**

| | | | |
|---|---|---|---|
| ១-លោក | **ឃីម ប៉ូខាន់** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៣០.០០០ ដុល្លារ |
| ២-លោកជំទាវ | **ឆោម ចន្ថា ឌូ ផល្លា** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៣-លោក | **សំ គេង** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៤-លោក | **ហួត ខូន** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៥-លោក | **ទ៉េត ទឹម** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ១០.០០០ ដុល្លារ |

**ខ. មេដាយប្រាក់ស្ថាបនាជាតិចំនួន ០៤ គ្រឿង ប្រគេន និងផ្តល់ជូន :**

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | **ឡាយ ជឿន** | ព្រះគ្រូធម្មាចារ្យ | បច្ច័យចំនួន ៦.០០០ ដុល្លារ |
| ២-លោក | **ឆិញ ថុ** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៧.០០០ ដុល្លារ |

| | | | |
|---|---|---|---|
| ៣-លោក **ប៊ិល ហ្វូលី** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន | ៦.០០០ ដុល្លារ |
| ៤-លោក **យូ យ៉េ** | អាចារ្យវត្តអារញ្ញសាគរ | ថវិកាចំនួន | ៦.០០០ ដុល្លារ |

**គ. មេដាយសិរីវឌ្ឍិស្ថាបនាជាតិចំនួន ១៤ គ្រឿង ប្រគេន និងផ្តល់ជូន :**

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ **សេង ចាន់** | ព្រះគ្រូសូត្រឆ្វេងវត្តអារញ្ញសាគរ | បច្ច័យចំនួន | ១.០០០ ដុល្លារ |
| ២-ព្រះតេជគុណ **សុភ ឆេង** | គង់នៅវត្តអារញ្ញសាគរ | បច្ច័យចំនួន | ១.០០០ ដុល្លារ |
| ៣-ឯកឧត្តម **អ៊ិន វឌ្ឍសេរី** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន | ៣.០០០ ដុល្លារ |
| ៤-លោក **ហ៊ិន ឌុច** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន | ៣.០០០ ដុល្លារ |
| ៥-លោក **ឃ្លោក គួយ** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន | ៣.០០០ ដុល្លារ |
| ៦-លោក **ស៊ឹ ស៊ីម** | អាចារ្យវត្តអារញ្ញសាគរ | ថវិកាចំនួន | ១.៥០០ ដុល្លារ |
| ៧-លោកស្រី **រ័ត្ន ស្រី** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន | ១.៥០០ ដុល្លារ |
| ៨-លោក **ភង សុខ** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន | ១.៥០០ ដុល្លារ |
| ៩-លោក **សួន ថ្វី** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន | ១.៥០០ ដុល្លារ |
| ១០-ឧបាសក **យូ ស្រេង** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន | ១.៥០០ ដុល្លារ |
| ១១-លោក **សាយ នួម** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន | ១.០០០ ដុល្លារ |
| ១២-លោក **អ៊ុំ ចាត** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន | ១.០០០ ដុល្លារ |
| ១៣-លោក **មួង មាន** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន | ១.០០០ ដុល្លារ |
| ១៤-លោក **នុត ឈៀង** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន | ១.០០០ ដុល្លារ |

**មាត្រា ២ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.០០៩៥៣...សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការបង្កើត និងដាក់ឱ្យដំណើរការអង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត.០៨០៧/៣៩៣ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៧ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០២ ស្តីពីការបង្កើតឧត្តម-ក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១១៣/១១៩០ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការសម្រួលព្រះរាជក្រឹត្យលេខ នស/រកត.០៨០៧/៣៩៣ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៧ ស្តីពីការកែសម្រួល

ព្រះរាជក្រឹត្យលេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

- បានឃើញ អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ២៦៧ អនក្រ.បក ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការផលិតភាពកម្ពុជា
- បានឃើញ អនុក្រឹត្យលេខ ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងដាក់ឱ្យអនុវត្តអង្គភាពថវិកា
- បានឃើញ ប្រកាសលេខ ២២៣ សហវ.ប្រក ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពក្រោមឱ្យវាទអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញ ប្រកាសលេខ ៨៥៦ សហវ.ប្រក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការរៀបចំ និងចាប់ផ្តើមអនុវត្តអង្គភាពថវិកា
- បានឃើញ ប្រកាសលេខ ៤៤០ សហវ.ប្រក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមការងារថវិកា របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ សេចក្តីសម្រេច លេខ ០០៨ សហវ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការតែងតាំងសមាសភាពក្រុមការងារថវិកា កម្រិតថ្នាក់ដឹកនាំក្រសួង
- បានឃើញ សេចក្តីសម្រេចលេខ ០០៩ សហវ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការតែងតាំងសមាសភាពក្រុមការងារថវិកា កម្រិតថ្នាក់ដឹកនាំអង្គភាពថវិកា
- បានឃើញ សេចក្តីសម្រេចលេខ ០១០ សហវ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការតែងតាំងសមាសភាពក្រុមការងារថវិកា កម្រិតបច្ចេកទេស
- បានឃើញ សេចក្តីសម្រេចលេខ ០១១ សហវ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការតែងតាំងសមាសភាពក្រុមការងារថវិកា កម្រិតផ្ទៃក្នុងអង្គភាពថវិកា

## សម្រេច

**ប្រការ១.–**

ត្រូវបានបង្កើតនិងដាក់ឱ្យដំណើរការអង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចខាងក្រោម÷

១. ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

២. គណៈកម្មាធិការផលិតភាពកម្ពុជា

៣. វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការ នៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី៣០ខែធ្នូ ឆ្នាំ២០១៥

រដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...០១៩...សហវ.ប្រក

## ប្រកាស

## ស្តីពី

## ស្តង់ដារនៃសេវាសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញ អនុក្រឹត្យលេខ ៨៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងធានាប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាព នៃការផ្តល់សេវាសាធារណៈ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ២.-**

ប្រកាសនេះ មានគោលដៅកំណត់ស្តង់ដារនៃសេវាសាធារណៈ ដែលផ្តល់ដោយអគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្ត ចំពោះសេវាសាធារណៈ ដែលត្រូវផ្តល់ដោយអគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៤.-**

សេវាសាធារណៈ សំដៅដល់សេវាដែលត្រូវផ្តល់ដោយអគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមមុខងារនិងភារកិច្ចជាធរមាន ក្នុងគោលដៅបម្រើផលប្រយោជន៍សាធារណៈ ជូនដល់សាធារណជនជារូបវន្តបុគ្គល ឬនីតិបុគ្គល ដោយគិតកម្រៃ ឬដោយឥតកម្រៃ។

## ជំពូកទី២

## កម្រងសេវាសាធារណៈ

**ប្រការ៥.-**

កម្រងសេវាសាធារណៈ គឺជាការចងក្រងនូវរាល់សេវាសាធារណៈដែលត្រូវផ្តល់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈអគ្គនាយកដ្ឋាននិងអង្គភាពជំនាញពាក់ព័ន្ធ ដោយបញ្ជាក់នូវព័ត៌មានជាសារវន្ត ដូចខាងក្រោម÷

- ឈ្មោះ ឬប្រភេទសេវាសាធារណៈ
- តម្លៃនៃការប្រើប្រាស់សេវាសាធារណៈ
- លក្ខខណ្ឌក្នុងការទទួលបានសេវាសាធារណៈ
- សុពលភាពនៃសេវាសាធារណៈ
- ឯកសារតម្រូវដែលអ្នកប្រើប្រាស់សេវាសាធារណៈ ត្រូវភ្ជាប់ជាមួយពាក្យស្នើសុំ
- លិខិតបទដ្ឋានគតិយុត្តដែលជាមូលដ្ឋាននៃការផ្តល់សេវាសាធារណៈ
- ឈ្មោះនិងអាសយដ្ឋានអង្គភាព ដែលផ្តល់សេវាសាធារណៈ
- មធ្យោបាយទំនាក់ទំនងសម្រាប់ទទួលបានសេវាសាធារណៈដែលរួមមានជាអាទិ៍ លេខទូរសព្ទ គេហទំព័រ និងសារអេឡិកត្រូនិក
- ពេលម៉ោងបំពេញការងារ
- រយៈពេលនៃការផ្តល់សេវាសាធារណៈ
- ទីកន្លែងទទួលពាក្យបណ្តឹងនិងរយៈពេលនៃការដោះស្រាយបណ្តឹង
- ព័ត៌មានផ្សេងទៀតតាមការចាំបាច់។

គំរូតារាងព័ត៌មានអំពីសេវាសាធារណៈ ត្រូវបានកំណត់ជាឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

**ប្រការ៦.-**

អគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចរៀបចំ ចងក្រង និងបោះពុម្ពផ្សាយកម្រងសេវាសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីប្រើប្រាស់ជាផ្លូវការនិងផ្សព្វផ្សាយជាសាធារណៈ។

**ប្រការ៧.-**

អគ្គនាយកដ្ឋាននិងអង្គភាពផ្តល់សេវាសាធារណៈ មានភារកិច្ចបំពេញតារាងព័ត៌មានអំពីសេវាសាធារណៈដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីផ្ញើមកអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យ រៀបចំ ចងក្រង និងបោះពុម្ពផ្សាយ ដាក់ឱ្យប្រើប្រាស់ជាផ្លូវការ។

## ជំពូកទី៣

## ច្រកចេញចូលតែមួយ

**ប្រការ៨.-**

ត្រូវបានបង្កើតច្រកចេញចូលតែមួយ ដែលសរសេរជាអក្សរកាត់ថា **ច.ច.ម.** ដើម្បីធ្វើជាកន្លែងប្រមូលផ្តុំព័ត៌មាន ផ្តល់ព័ត៌មាន និងផ្តល់សេវាកម្មជាធរមានពាក់ព័ន្ធសេវាសាធារណៈ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជូនដល់សាធារណជន ទាំងរូបវន្តបុគ្គល និងនីតិបុគ្គល។

**ច.ច.ម.** ទីស្តីការក្រសួង ត្រូវដឹកនាំនិងសម្របសម្រួលដោយនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន និងចូលរួមគាំទ្រដោយមន្ត្រីបង្គោលនៃអគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ ដែលមានទីតាំងស្ថិតក្នុងបរិវេណនៃទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អគ្គនាយកដ្ឋាននិងអង្គភាព ដែលមានទីតាំងស្ថិតនៅក្នុងបរិវេណ នៃទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចចាត់តាំងមន្ត្រីបង្គោលរបស់ខ្លួនចេញពីលេខាធិការដ្ឋាន នាយកដ្ឋាន ឬអង្គភាពទទួលបន្ទុករដ្ឋបាលរបស់ខ្លួន ដើម្បីចូលរួមគាំទ្រដំណើរការ **ច.ច.ម.** ទីស្តីការក្រសួង។

នាយកដ្ឋាន ឬអង្គភាពទទួលបន្ទុករដ្ឋបាល នៃអគ្គនាយកដ្ឋាន ដែលស្ថិតនៅក្រៅបរិវេណនៃទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញមុខងារជា **ច.ច.ម.** ក្រៅទីស្តីការក្រសួង តាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ មានភារកិច្ចរៀបចំច្រកចេញចូលតែមួយ ដែលត្រូវទទួលខុសត្រូវដោយលេខាធិការដ្ឋាន នាយកដ្ឋាន ឬអង្គភាពទទួលបន្ទុករដ្ឋបាល និងដាក់ឱ្យដំណើរការ នៅតាមសាខា ឬអង្គភាពមូលដ្ឋានរបស់ខ្លួន ដោយអនុលោមតាមស្មារតីនៃប្រកាសនេះ។

**ប្រការ៩.-**

**ច.ច.ម.** ទីស្តីការក្រសួង មានភារកិច្ច ដូចខាងក្រោម÷

- ផ្តល់ព័ត៌មាន ទម្រង់បែបបទ និងសម្របសម្រួលនីតិវិធី នៃការផ្តល់សេវាសាធារណៈ ជូនសាធារណជន
- ទទួលពាក្យសុំ ឬសំណើសុំសេវាសាធារណៈ ពីសាធារណជន
- ពិនិត្យ និងបញ្ជាក់ភាពគ្រប់គ្រាន់និងត្រឹមត្រូវតាមលក្ខណៈរដ្ឋបាល នៃសំណើសុំនិងសំណុំឯកសារពាក់ព័ន្ធសេវាសាធារណៈ

- បែងចែក និងបញ្ជូនពាក្យសុំ សំណើសុំ និងសំណុំឯកសារពាក់ព័ន្ធ ទៅកាន់អគ្គនាយកដ្ឋានឬអង្គភាពជំនាញពាក់ព័ន្ធ
- ទទួលប្រាក់កម្រៃសេវាសាធារណៈ ឬបង្កាន់ដៃបង់ប្រាក់ ពីអ្នកប្រើប្រាស់សេវាធារណៈ តាមនីតិវិធីជាធរមាន
- ប្រគល់សេចក្តីសម្រេចពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈជាអាទិ៍ លិខិតគតិយុត្ត អាជ្ញាប័ណ្ណ ជូនទៅអ្នកប្រើប្រាស់
- រៀបចំនិងបូកសរុបរបាយការណ៍ស្តីពីការផ្តល់សេវាសាធារណៈ និងរបាយការណ៍ស្តីពីចំណូលពីការផ្តល់សេវាសាធារណៈ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមនីតិវិធីជាធរមាន
- ទទួលមតិយោបល់ និងមតិកែលម្អស្ថាបនា ពីអ្នកប្រើប្រាស់សេវាសាធារណៈ។

**ប្រការ១០.-**

មន្ត្រីបង្គោល នៃអគ្គនាយកដ្ឋាននិងអង្គភាពក្នុងបរិវេណនៃទីស្តីការក្រសួង មានភារកិច្ច ដូចតទៅ÷

- ពិនិត្យ និងបញ្ជាក់ភាពគ្រប់គ្រាន់និងត្រឹមត្រូវតាមលក្ខណៈរដ្ឋបាល នៃសំណើសុំនិងសំណុំឯកសារពាក់ព័ន្ធសេវាសាធារណៈ
- លើកយោបល់ និងបញ្ជូនសំណុំឯកសារស្នើសុំសេវាសាធារណៈ ទៅអគ្គនាយកដ្ឋាន ឬអង្គភាពជំនាញរបស់ខ្លួន ដើម្បីមានចំណាត់ការបន្ត តាមនីតិវិធីផ្ទៃក្នុងជាធរមាន
- ផ្តល់ព័ត៌មាន និងសម្របសម្រួលការផ្តល់ព័ត៌មាន អំពីវិធាននិងនីតិវិធីនៃការផ្តល់សេវាសាធារណៈ
- សម្របសម្រួលការបញ្ជូនសេចក្តីសម្រេចពាក់ព័ន្ធការផ្តល់សេវាសាធារណៈជាអាទិ៍ លិខិតគតិយុត្ត និងអាជ្ញាបណ្ណ ជូន **ច.ច.ម.** ទីស្តីការក្រសួង។

**ប្រការ១១.-**

**ច.ច.ម.** ក្រៅទីស្តីការក្រសួង មានភារកិច្ច ដូចខាងក្រោម÷

- ផ្តល់ព័ត៌មាន ទម្រង់បែបបទ និងសម្របសម្រួលនីតិវិធី នៃការផ្តល់សេវាសាធារណៈ ជូនសាធារណជន
- ទទួលពាក្យសុំ ឬសំណើសុំសេវាសាធារណៈ ពីសាធារណជន
- ពិនិត្យនិងបញ្ជាក់ភាពគ្រប់គ្រាន់និងត្រឹមត្រូវតាមលក្ខណៈរដ្ឋបាល នៃសំណើសុំនិងសំណុំឯកសារពាក់ព័ន្ធសេវាសាធារណៈ
- បែងចែក និងបញ្ជូនពាក្យសុំ សំណើសុំ និងសំណុំឯកសារពាក់ព័ន្ធ ទៅកាន់នាយកដ្ឋាន ឬអង្គភាពជំនាញពាក់ព័ន្ធ ដើម្បីមានចំណាត់ការបន្ត តាមនីតិវិធីផ្ទៃក្នុងជាធរមាន
- ទទួលប្រាក់កម្រៃសេវាសាធារណៈ និងប្រគល់បង្កាន់ដៃបង់ប្រាក់ ដល់អ្នកប្រើប្រាស់សេវាធារណៈ តាមនីតិវិធីជាធរមាន
- ប្រគល់សេចក្តីសម្រេចពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈជាអាទិ៍ លិខិតគតិយុត្ត អាជ្ញាបណ្ណ ជូនទៅអ្នកប្រើប្រាស់

- រៀបចំនិងបូកសរុបរបាយការណ៍ស្តីពីការផ្តល់សេវាសាធារណៈ និងរបាយការណ៍ស្តីពីចំណូលពីសេវាធារណៈ របស់អគ្គនាយកដ្ឋាន ឬអង្គភាពរបស់ខ្លួន ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមនីតិវិធីជាធរមាន
- ទទួលមតិយោបល់ និងមតិកែលម្អស្ថាបនា ពីអ្នកប្រើប្រាស់សេវាសាធារណៈ។

**ប្រការ១២.-**

ការចាត់តាំងសមាសភាព **ច.ច.ម.** ទីស្តីការនិងក្រៅទីស្តីការក្រសួង ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៤
## គោលការណ៍នៃការផ្តល់សេវាសាធារណៈ

**ប្រការ១៣.-**

ការផ្តល់សេវាសាធារណៈ ត្រូវអនុលោមតាមគោលការណ៍ ដូចខាងក្រោម÷

- កម្រៃសេវាសាធារណៈ និងរយៈពេលនៃការផ្តល់សេវា ត្រូវកំណត់ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ឬតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ព័ត៌មានស្តីពីកម្រៃសេវា, រយៈពេល, លក្ខខណ្ឌនៃការផ្តល់សេវាសាធារណៈ, សុពលភាព, និងនីតិវិធីប្តឹងតវ៉ា ត្រូវមានការផ្សព្វផ្សាយទូលំទូលាយ និងអាចទទួលយកបានដោយងាយ ដោយអ្នកប្រើប្រាស់ នៅតាម **ច.ច.ម.**
- សេវាសាធារណៈ ត្រូវផ្តល់ជូនអ្នកប្រើប្រាស់ តាមលក្ខខណ្ឌនិងទាន់ពេលវេលាកំណត់ជាធរមាន
- សេវាសាធារណៈ ត្រូវបង្កើនប្រសិទ្ធភាពបន្ថែម តាមរយៈបច្ចេកវិទ្យាព័ត៌មាន ជាអាទិ៍គេហទំព័រ អ៊ីមែល ទូរស័ព្ទ ឬទូរសារ
- សេវាសាធារណៈ ត្រូវផ្តល់ជូនដោយផ្ទាល់ចំពោះអ្នកប្រើប្រាស់ ឬតាមរយៈតំណាងស្របច្បាប់ ដោយពុំត្រូវឱ្យមានអន្តរការីឡើយ លើកលែងមានការអនុញ្ញាតដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៥
## ការត្រួតពិនិត្យនិងសវនកម្ម

**ប្រការ១៤.-**

**ច.ច.ម.** មានភារកិច្ចរៀបចំរបាយការណ៍ស្តីពីការផ្តល់សេវាសាធារណៈ ប្រចាំត្រីមាស និងប្រចាំឆ្នាំ គោរពជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

គំរូនៃរបាយការណ៍ស្តីពីការផ្តល់សេវាសាធារណៈ ត្រូវបានកំណត់ជាឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

**ច.ច.ម.** ត្រូវរៀបចំប្រព័ន្ធស្វ័យវាយតម្លៃនៃការផ្តល់សេវាសាធារណៈរបស់ខ្លួន ដើម្បីទទួលបានការវាយតម្លៃដោយផ្ទាល់ពីអ្នកប្រើប្រាស់សេវាសាធារណៈ សំដៅកែលម្អគុណភាពនៃសេវាសាធារណៈ ដែលជាសមត្ថកិច្ចរបស់ខ្លួន។

**ប្រការ១៥.-**

អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចធ្វើសវនកម្មតាមផែនការសវនកម្មជាធរមាន អំពីអនុលោមភាពតាមស្តង់ដារសេវាសាធារណៈ នៃការផ្តល់សេវាសាធារណៈរបស់ **ច.ច.ម.** តាមវិធាននិងនីតិវិធីជាធរមាន ដើម្បីលើកអនុសាសន៍សវនកម្ម ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យនិងសម្រេចដាក់ឱ្យអនុវត្ត។

## ជំពូកទី៦
## ការទទួលមតិកែលម្អ និងបណ្តឹងតវ៉ា

**ប្រការ១៦.-**

មតិកែលម្អរបស់អ្នកប្រើប្រាស់សេវាសាធារណៈ ត្រូវពិនិត្យ រៀបចំ និងបូកសរុប ដោយ **ច.ច.ម.** តាមនីតិវិធីផ្ទៃក្នុងជាធរមាន ដើម្បីមានចំណាត់ការដោះស្រាយ។

បណ្តឹងតវ៉ាអំពីការផ្តល់សេវាសាធារណៈ ត្រូវពិនិត្យនិងដោះស្រាយ ដោយអគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធតាមវិធាននិងនីតិវិធីជាធរមាន។

ដើម្បីធានាប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព នៃការដោះស្រាយបណ្តឹងតវ៉ា និងមតិកែលម្អរបស់អ្នកប្រើប្រាស់សេវាសាធារណៈ អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង អាចធ្វើសវនកម្ម តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីលើកអនុសាសន៍សវនកម្ម ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យនិងសម្រេច។

កន្លែងទទួលមតិកែលម្អនិងបណ្តឹងតវ៉ា ត្រូវរៀបចំឱ្យបានសមស្របនិងងាយស្រួល សម្រាប់អ្នកប្រើប្រាស់សេវាសាធារណៈ។

## ជំពូកទី៧
## ទោសប្បញ្ញត្តិ

**ប្រការ១៧.-**

មន្ត្រីរាជការសាធារណៈគ្រប់ប្រភេទ និងគ្រប់ឋានៈ រួមទាំងមន្ត្រីជាប់កិច្ចសន្យា ដែលមិនគោរពឬបំពានបទប្បញ្ញត្តិពាក់ព័ន្ធស្តង់ដារសេវាសាធារណៈ ដូចមានចែងក្នុងប្រកាសនេះ ត្រូវទទួលទណ្ឌកម្មរដ្ឋបាលតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ដោយមិនគិតដល់ទណ្ឌកម្មព្រហ្មទណ្ឌ និងសំណងរដ្ឋប្បវេណី ជាអាទិ៍ចំពោះសកម្មភាពដែលបានប្រព្រឹត្ត ឬចូលរួមក្នុងការប្រព្រឹត្តអំពើ ដូចខាងក្រោម÷

- ការយកប្រាក់កម្រៃសេវាសាធារណៈលើសពីការកំណត់ដោយបទដ្ឋានគតិយុត្តជាធរមាន
- ការរារាំង ការពន្យឺត ឬការបង្អង់ដំណើរការនៃការផ្តល់សេវាសាធារណៈ
- ការមិនគោរព ឬបំពានគោលការណ៍និងនីតិវិធីនៃការផ្តល់សេវាសាធារណៈ
- ការរារាំង ឬការបង្អាក់ដំណើរការសវនកម្ម ដើម្បីធានាអនុលោមភាព នៃការផ្តល់សេវាសាធារណៈ។

## ជំពូកទី៨
## អន្តរប្បញ្ញត្តិ

**ប្រការ១៨.-**

អគ្គនាយកដ្ឋាននិងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំ **ច.ច.ម.** តាមភារកិច្ចរៀងៗខ្លួន និងដាក់ឱ្យដំណើរការ ប្រកបដោយប្រសិទ្ធភាពនិងនិរន្តរភាព ចាប់ពីឆ្នាំ២០១៦ តទៅ តាមជំហានដាក់ស្តែងសម្រេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ឧបសម្ព័ន្ធនៃប្រកាសនេះ អាចត្រូវបានកែសម្រួល តាមការចាំបាច់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៩

## អវសានប្បញ្ញត្តិ

**ប្រការ១៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២០.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០១៥

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី១ នៃប្រកាសលេខ សហវ.ប្រក
ចុះថ្ងៃទី ខែ ឆ្នាំ ស្តីពីស្តង់ដារនៃ
សេវាសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## គំរូតារាងព័ត៌មានអំពីសេវាសាធារណៈ

| (ឈ្មោះសេវា) | |
|---|---|
| **បរិយាយអំពីសេវា** | |
| មូលដ្ឋានគតិយុត្ត | |
| លក្ខខណ្ឌក្នុងការទទួលសេវាសាធារណៈ | |
| កម្រៃសេវាសាធារណៈ | |
| សុពលភាពនៃសេវាសាធារណៈ | |
| រយៈពេលនៃការផ្តល់សេវាសាធារណៈ | |
| ឯកសារតម្រូវ | |
| អគ្គនាយកដ្ឋាន ឬអង្គភាពទទួលបន្ទុកពិនិត្យនិងសម្រេចផ្តល់សេវា និងអាសយដ្ឋាន | |
| ពេលម៉ោងបំពេញការងារ | |
| ទីកន្លែងទទួលនិងរយៈពេលដាក់ពាក្យបណ្តឹងតវ៉ា ពាក់ព័ន្ធសេវា (ក្នុងករណីដែលមាន) | |
| អាសយដ្ឋានយន្តការច្រកចេញចូលតែមួយ | |

ឧបសម្ព័ន្ធទី២ នៃប្រកាសលេខ សហវ.ប្រក ចុះថ្ងៃទី
ខែ ឆ្នាំ ស្តីពីស្តង់ដារនៃសេវាសាធារណៈរបស់ក្រសួង
សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**ច្រកចេញចូលតែមួយ .....**

**របាយការណ៍**
**ស្តីពី**
**ការផ្តល់សេវាសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រចាំត្រីមាស..... /ឆមាស...../ឆ្នាំ.....**
**របស់ច្រកចេញចូលតែមួយ .....**

**ក. វឌ្ឍនភាព**

| ឈ្មោះសេវាសាធារណៈ | អង្គភាពទទួលបន្ទុកផ្តល់សេវាសាធារណៈ | ចំនួនពាក្យស្នើសុំ | សេវាសាធារណៈដែលបានផ្តល់ | សេវាសាធារណៈដែលបដិសេធន៍ | សេវាសាធារណៈដែលពុំទាន់ផ្តល់ | | ចំនួនការប្តឹងតវ៉ា | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | ពុំទាន់ដល់កាលកំណត់ | ការយឺតយ៉ាវ | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |

**ខ. បញ្ហាប្រឈម**

.....

**គ. សំណើដំណោះស្រាយ**

.....

ឃ. សន្និដ្ឋាន

.....

ភ្នំពេញ, ថ្ងៃទី ..... ខែ ..... ឆ្នាំ .....

**ប្រធានច្រកចេញចូលតែមួយ**

ភ្នំពេញ, ថ្ងៃទី ..... ខែ ..... ឆ្នាំ .....

**បានពិនិត្យនិងឯកភាព**

**ប្រធានអង្គភាពទទួលបន្ទុករដ្ឋបាល**

ភ្នំពេញ, ថ្ងៃទី ..... ខែ ..... ឆ្នាំ .....

**បានឃើញនិងឯកភាព**

**អគ្គលេខាធិការ/អគ្គនាយក**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: [illegible] ឧស.[illegible]-១០

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្តូរប្រកាសបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន ម៉ាកាឡូត ហ្គាមេន (ខេមបូឌា) ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ម៉ាកាឡូត ហ្គាមេន (ខេមបូឌា) (MAKALOT GARMENTS (CAMBODIA) CO., LTD.) តំណាងដោយ លោក **CHEN, KUO-LONG** បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅ ក្នុងសួនឧស្សាហកម្មវឌ្ឍនៈ អគារ(B) ផ្លូវចោមចៅ ភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
| --- | --- |
| សម្លៀកបំពាក់ | ១៤១០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្ដីណែនាំស្ដីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ** ៖ "រោងចក្រកាត់ដេរសម្លៀកបំពាក់ ម៉ាកាឡូត ហ្គាមេន (ខេមបូឌា)"

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្ដើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្ដូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្ដូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្ដូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្ដីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្ដល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់ នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្ដាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសលេខ ០០៥៣ ឧស.កឧ.ប្រក.៦ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៤ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងវិញ្ញាបនបត្រអនុញ្ញាតដំណើរការសាខារោងចក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៦ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ស្តីពីការបង្កើតរោងចក្រកាត់សម្លៀកបំពាក់ របស់ក្រុមហ៊ុន ម៉ាកាឡូតហ្គាមេន (ខេមបូឌា) ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋមន្ត្រីស្តីទី**

**សាត សាមី**

**<u>ចម្លងជូន៖</u>**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងបរិស្ថាន
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -សាលារាជធានីភ្នំពេញ
  "ដើម្បីជូនជ្រាប"
- -ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ...ឧស.ក...១០

រាជធានីភ្នំពេញ, ថ្ងៃទី...ខែតុលា ឆ្នាំ២០១៥

## ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្លង់ប្រកាសបង្កើតសាខារោងចក្រកាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន ម៉ាកាឡុត ហ្គាមេន (ខេមបូឌា) ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥។

## សម្រេច

